ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
=======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
=======

## ស្ថានតំណាងកម្ពុជាប្រចាំប្រទេសវៀតណាម សម្របសម្រួលជួយដល់ពលករខ្មែរ ១៧នាក់

* * * * * *

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសវៀតណាម បានរាយការណ៍ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ថាមានពលករខ្មែរចំនួន **១៧នាក់** ដូចខាងក្រោម ត្រូវបាននគរបាលសមុទ្រវៀតណាមឃាត់ខ្លួន កាលពីថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៧ ក្នុងពេលឃាត់នាវារបស់ថៃ ០៣គ្រឿង (VOR LUCKY, BPP3, HAKUYO MARU) និងនាវានេសាទវៀតណាម ០៤គ្រឿង ដែលកំពុងធ្វើសកម្មភាពជួញដូរ និងដឹកជញ្ជូនប្រេងខុសច្បាប់ នៅក្នុងដែនសមុទ្រវៀតណាម។ បច្ចុប្បន្នពលករខ្មែរទាំង១៧នាក់ កំពុងត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅលើកោះ Phu Quoc ខេត្ត Kien Giang ប្រទេសវៀតណាម។

| | | | |
|---|---|---|---|
| ១. | ឈ្មោះ ស្នា | អាយុ ៣០ឆ្នាំ | មកពីខេត្តសៀមរាប |
| ២. | ឈ្មោះ ប៊ុន | អាយុ ៣៥ឆ្នាំ | មកពីខេត្តសៀមរាប |
| ៣. | ឈ្មោះ សុជា | អាយុ ២៤ឆ្នាំ | មកពីខេត្តសៀមរាប |
| ៤. | ឈ្មោះ ទូល | អាយុ ២៣ឆ្នាំ | មកពីខេត្តសៀមរាប |
| ៥. | ឈ្មោះ ចិន រិន | អាយុ ២៥ឆ្នាំ | មកពីខេត្តសៀមរាប |
| ៦. | ឈ្មោះ អ៊ុំ វុធ | អាយុ ៣៥ឆ្នាំ | មកពីខេត្តសៀមរាប |
| ៧. | ឈ្មោះ កេង ហឿ | អាយុ ៣៤ឆ្នាំ | មកពីខេត្តសៀមរាប |
| ៨. | ឈ្មោះ ឡឿង គី | អាយុ ២៦ឆ្នាំ | មកពីខេត្តសៀមរាប |
| ៩. | ឈ្មោះ គង់ រ៉ា | អាយុ ២៤ឆ្នាំ | មកពីខេត្តសៀមរាប |
| ១០. | ឈ្មោះ ហុង សុភាព | អាយុ ៣០ឆ្នាំ | មកពីខេត្តសៀមរាប |
| ១១. | ឈ្មោះ ផាត | អាយុ ២៥ឆ្នាំ | មកពីខេត្តសៀមរាប |
| ១២. | ឈ្មោះ សួល | អាយុ ៥០ឆ្នាំ | មកពីខេត្តកំពង់ធំ |
| ១៣. | ឈ្មោះ សៀត | អាយុ ១៨ឆ្នាំ | មកពីខេត្តកំពង់ធំ |
| ១៤. | ឈ្មោះ រៀម | អាយុ ២៥ឆ្នាំ | មកពីខេត្តកំពង់ធំ |
| ១៥. | ឈ្មោះ អេង ធួល | អាយុ ២៣ឆ្នាំ | មកពីខេត្តកំពង់ចាម |
| ១៦. | ឈ្មោះ ឆាត | អាយុ ៣៥ឆ្នាំ | មកពីខេត្តកំពង់ចាម |
| ១៧. | ឈ្មោះ គា ធី | អាយុ ៣៨ឆ្នាំ | មកពីខេត្តកោះកុង |

ក្រោយទទួលបានដំណឹងពីការឃាត់ខ្លួននេះ ស្ថានទូតបានជូនដំណឹង និងស្នើស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងហូជីមិញ ចុះទៅជួបសួរសុខទុក្ខពលករខ្មែរទាំង ១៧នាក់ និងសម្របសម្រួលជាមួយអាជ្ញាធរវៀតណាម ដើម្បីរៀបចំមាតុភូមិនិវត្តន៍ពួកគាត់មកកម្ពុជាវិញ។

ភ្នំពេញ, ថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ